KO 3315
TSL BOX 4

# ករណី ចាន់ ប៊ុនណា

អាយុ ៤០ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

- អតីត: កម្មកររោងចក្រ កង់ឡានតាខ្មៅ ។
- បច្ចុប្បន្ន: កម្មករ "ក១" ។

- ទទួលការអប់រំបន្តបន្ទាប់ពីឈ្មោះ គឹម សុផានី -សេ ៧នៃកម្មករ ក១
បច្ចុប្បន្ន : ចាប់ខ្លួន - នូវទ្រឹស្តី របបលោកសេរី នូវឥទ្ធិពលចក្រ
ពត្តិអាមេរិកក្នុងសកលលោក នូវជីវភាពហ៊ឺហា មានលុយចាយ ។

៥.៧៤ • ចូល សេ អ៊ី អា ទៅក្រសួងឃោសនាការ
អ្នកនាំចូល គឹម សុផានី និង ទៅ កែម - សេ សក្តិ ៤ កន្លះ មេ
ខ្មែរ សេ អ៊ី អា របស់ គឹម សុផានី បច្ចុប្បន្ន : មិនដឹង -
អ្នកទទួលស្គាល់ ថោង លឹមហួង - សេ នាយកក្រសួងឃោសនាការ
បច្ចុប្បន្ន មិនដឹង -
ប្រាក់ខែ ៥០ ដុល្លារ
ភារកិច្ច ឃោសនា និងចលនាកម្មករឱ្យគាំទ្ររបបសាធារណរដ្ឋស្រ
ឡាញ់របបលោកសេរី ឱ្យស្អប់កុម្មុយនីស្ត ខ្មែរក្រហម និង
ស៊ើបការណ៍រកបណ្តាញខ្មែរក្រហមក្នុង និង ក្រៅរោងចក្រ ។

សកម្មភាព : ក្រោយ ១៧.៤.៧៥ :
ធ្វើសកម្មភាព សេ អ៊ី អា ក្នុងក្រុម គឹម សុផានី ។

- បានឃោសនាវាយប្រហារបដិវត្ត ថា ក្រ ស៊ី អង្គរកំប៉ុងឱ្យធ្វើការដូចម៉ាស៊ីន បំបិតសិទ្ធសេរីភាព គ្មានសាលាវិទ្យាល័យ មហាវិទ្យាល័យ ។
- បានចលនាកម្មករឱ្យលាក់បច្ចេកទេស លាក់ចំណេះលាយវត្ថុធាតុធ្វើកង់ឡាន និងឱ្យវាយប្រហារកម្មាភិបាលដឹកនាំរោងចក្រ ថាត្រួតត្រា បញ្ជាផ្តាច់ការជិះជាន់កម្មករចាស់ ។
- បានធ្វើឱ្យ ខូចពោះវៀនកង់ឡាន អស់ ៣០ ។
- បានធ្វើឱ្យខូចគុណភាព កង់ឡាន អស់ ១០ ។
- បានធ្វើឱ្យខូចគុណភាពកៅស៊ូកិនហើយអស់ ៥០០ គីឡូក្រាម ។